**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

# មតិស្វាគមន៍
# ក្នុងសិក្ខាសាលាថ្នាក់ជាតិ
# ស្តីពី
# ការពង្រឹងការអនុវត្តច្បាប់ដើម្បីយុត្តិធម៌ជនរងគ្រោះ

ដោយលោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់ ថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៦

ម៉ោង ៨.៣០ ព្រឹក

នាងខ្ញុំសូមអនុញ្ញាតគោរព សម្តេចក្រឡាហោម ស ខេង នាយករដ្ឋមន្ត្រីស្តីទី តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតី តេជោ នាយករដ្ឋមន្ត្រី និងជាប្រធាន គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពជួញដូរមនុស្ស គ.ជ.ប.ជ ជាទីគោរពដ៏ខ្ពង់ខ្ពស់

សូមគោរពឯកឧត្តមរដ្ឋមន្ត្រី ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឯកឧត្តម លោកជំទាវរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង អគ្គស្នងការរង ប្រធាននាយកដ្ឋាន ចៅក្រម ព្រះរាជអាជ្ញា ស្នងការរង នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស ពីបណ្តារាជធានីខេត្ត ទូទាំងព្រះរាជាណាចក្រកម្ពុជា អង្គការដៃគូអភិវឌ្ឍន៍ អង្គការដៃគូពាក់ព័ន្ធទាំងអស់ ជាទីរាប់អាន

ថ្ងៃនេះ អគ្គលេខាធិការដ្ឋាន គណៈកម្មាជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានផ្តួចផ្តើមរៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពី **ការពង្រឹងការអនុវត្តច្បាប់ដើម្បីយុត្តិធម៌ជនរងគ្រោះ** នេះឡើង ក្នុងគោលបំណងពិនិត្យឡើងវិញ នូវភាពខ្វះចន្លោះនៃបទដ្ឋានច្បាប់ នីតិវិធី និងរបៀបរបបអនុវត្ត ឲ្យរឹតតែប្រសើរឡើង ដោយហេតុថា ព្រះរាជាណាចក្រកម្ពុជា ទទួលយកអនុសញ្ញា និងកតិកាសញ្ញាអន្តរជាតិជាច្រើន ដែលមានគោលដៅគោរពសិទ្ធិមនុស្ស សិទ្ធិកុមារ សិទ្ធិស្ត្រី និងការពារនូវវិនាសកម្មទាំងឡាយដល់មនុស្សជាតិ និងបានចងក្រងជាច្បាប់នានាជាច្រើន

សម្រាប់ការឆ្លើយតបទៅនឹងបញ្ហាទាំងឡាយ ដែលបង្ករជាបទល្មើសតូច ធំ ដែលនាំឲ្យប៉ះពាល់ដល់សេចក្តីសុខប្រជាពលរដ្ឋ និងសុវត្ថិភាពសង្គម និងបំផ្លាញដល់ធនធាន ការរីកចម្រើន ព្រមទាំងប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់មនុស្ស ក៏ដូចជាប្រទេសជាតិ ។

កន្លងមក យើងបានសង្កេតឃើញថា ទោះបីជាមានច្បាប់ច្រើនយ៉ាងណាក្តី ក៏ការអនុវត្ត នៅតែមិនទាន់អាចធ្វើឲ្យបទល្មើសថមថយ ហើយកើតមានដដែលៗទៅលើជនរងគ្រោះកាន់តែច្រើន ដែលក្នុងនោះ ជនរងគ្រោះទាំងឡាយ ជាពិសេសជនរងគ្រោះដោយអំពើជួញដូរមនុស្ស កម្របានទទួលនូវសំណងបដិទានសមស្របសម្រាប់ប៉ះប៉ូវការខូចខាតណាស់ ម្ល៉ោះហើយ បញ្ហានេះ បានបង្កនូវអវិភាពដល់ប្រជាពលរដ្ឋ ហើយកាន់តែភ័យខ្លាច ឬកាន់តែព្រងើយកន្តើយចំពោះការអនុវត្តច្បាប់ និងនៅតែប្រថុយប្រថាននឹងគ្រោះថ្នាក់ តាមគម្រូ តៗគ្នា ។

ដើម្បីកាត់បន្ថយនូវការបារម្ភទាំងនេះ ថ្ងៃនេះ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម នាយករដ្ឋមន្ត្រីស្តីទី** និងជាប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នាងខ្ញុំមានជំនឿថា សិក្ខាសាលថ្នាក់ជាតិនេះ នឹងទទួលបានផ្លែផ្កាយ៉ាងជាក់លាក់ និងល្អប្រសើរ តាមការគ្រោងទុកសំដៅដោះស្រាយបញ្ហាកង្វល់ទាំងនេះបាន ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណ ដល់ការចូលរួមគាំទ្រដល់ដំណើរការអង្គសិក្ខាសាលានេះ និងសូមគោរពជូនពរគណៈអធិបតី ភ្ញៀវកិត្តិយស សមាជិក សមាជិកាទាំងអស់ សូមទេវតាឆ្នាំថ្មីប្រទានពរបវរមហាប្រសើរ ដល់សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី សូមបានប្រកបដោយជោគជ័យ និងពុទ្ធពរទាំងបួនប្រការ គឺអាយុវណ្ណៈសុខៈពលៈកុំបីឃ្លៀងឃ្លាតឡើយ ។

សូមអរគុណ